# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខៈ ៨៧៣ សសរ**

## សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេសចំរុះ រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ/បក ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១ :** បង្កើតក្រុមការងារបច្ចេកទេសចំរុះ រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១-ឯកឧត្តម **ប្រាក់ សុខុន** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២-ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣-ឯកឧត្តម **ខឹម សោភ័ណ** | អគ្គនាយកមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា | សមាជិក |
| ៤-ឯកឧត្តម **សែម សុវណ្ណនី** | អគ្គលេខាធិការរងអាជ្ញាធរមីនកម្ពុជា-ទទួលបន្ទុកកិច្ចការបោសសំអាតមីននៃកងយោធពលខេមរភូមិន្ទ | សមាជិក |

| | | | |
|---|---|---|---|
| ៥-ឯកឧត្តម | **សេក សេដ្ឋា** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៦-ឯកឧត្តម | **ឡេង សុជា** | អគ្គលេខាធិការរង អាជ្ញាធរមីនកម្ពុជា | សមាជិក |
| ៧-ឯកឧត្តម | **ហេង រតនា** | អគ្គនាយករង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា | សមាជិក |
| ៨-ឯកឧត្តម | **ស ចាន់ធី** | ជំនួយការសម្តេចនាយករដ្ឋមន្ត្រី | សមាជិក |
| ៩-លោក | **នេត សុផល** | ប្រធាននាយកដ្ឋានផែនការ និងត្រួតពិនិត្យអាជ្ញាធរមីនកម្ពុជា | សមាជិក |
| ១០-លោក | **ចាន់ រដ្ឋា** | ប្រធាននាយកដ្ឋានទំនាក់ទំនង អាជ្ញាធរមីនកម្ពុជា | សមាជិក |

**ប្រការ២** : ក្រុមការងារបច្ចេកទេសចំរុះមានភារកិច្ចសម្របសម្រួលការងាររវាងរាជរដ្ឋាភិបាល និងប្រទេសផ្តល់ជំនួយលើវិស័យមីននៅកម្ពុជា ។

**ប្រការ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដែលមានចែងក្នុងប្រការមួយ ត្រូវអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចចែងក្នុងប្រការ ៣
- ឯកសារ-កាលប្បវត្តិ